# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ជាំងស៊ូ ផ្លូវជាតិលេខ៦

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើត **តំបន់សេដ្ឋកិច្ចពិសេស ជាំងស៊ូ ផ្លូវជាតិលេខ៦** ដែលមានទីតាំងស្ថិតនៅភូមិឈូក ឃុំគោករវៀង ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេស ជាំងស៊ូ ផ្លូវជាតិលេខ៦** មានទំហំ ៦៤៨ ៩២៦ម$^{២}$ (ប្រាំមួយរយប៉ែតសិបប្រាំបីពាន់ ប្រាំបួនរយម្ភៃប្រាំមួយ ម៉ែត្រការ៉េ) ដូចមានប្លង់បង្ហាញទីតាំងក្បាលដី និងតារាងនិយាមកាចំណុចព្រំដីភ្ជាប់ជាឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ចជាចំណែកភ្ជាប់អនុក្រឹត្យនេះ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស ជាំងស៊ូ ផ្លូវជាតិលេខ៦** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន សម្រាប់ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស ជាំងស៊ូ ផ្លូវជាតិលេខ៦** នេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៦កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ខែមេសា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីសូមចុះហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

សុខ ចិន្តាសោភា

កន្លែងទទួល÷

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
 នៃព្រះរាជាណាចក្រកម្ពុជា ប្រធាន ក.អ.ក
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៥
-ក្រុមហ៊ុន ហ្គោលដេន វីសសស៍ ប្រជីធី (ខេមបូឌា) លីមីធីត
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

## ប្លង់បង្ហាញទីតាំងដីគម្រោងស្នើសុំបង្កើតតំបន់សេដ្ឋកិច្ចពិសេស របស់ក្រុមហ៊ុន ហ្គោលដេន វែសសង់ ប្រជីធី (ខេមបូឌា) លីមីធីត

ភូមិសាស្ត្រស្ថិតនៅភូមិឈូក ឃុំគោករវៀង ស្រុកជើងព្រៃ ខេត្តកំពង់ចាម

មាត្រដ្ឋាន : 1:8,500




យោងលិខិតលេខ: ៤៥៩ ដនស/អដសក

ថ្ងៃ ..... ខែ ..... ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ២៤... ខែ ..... ឆ្នាំ ២០២៣

របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ថ្ងៃទី ២៣... ខែ ..... ឆ្នាំ ២០២៣

ប្រធានផ្នែកនិន្នន័យ និងគូរផែនទី

ផាន គឹមហៀង

បានឃើញ និងពិនិត្យត្រឹមត្រូវ

ថ្ងៃ ..... ខែ ..... ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ២៤... ខែ ..... ឆ្នាំ ២០២៣

ប្រធាននាយកដ្ឋានបច្ចេកទេស

ស្រុន ឌុំ

បានឃើញ និង ឯកភាព

ថ្ងៃ ..... ខែ ..... ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ..... ខែ ..... ឆ្នាំ ២០២៣

អគ្គនាយកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

សួន សុធា

តារាងនិយាមកាចំណុចព្រំដី

Projection UTM, Zone 48N, Datum WGS 84.

| Point_ID | Easting( m) | Northing (m) | Point_ID | Easting( m) | Northing (m) |
|---|---|---|---|---|---|
| 1 | 499515.517 | 1331504.668 | 35 | 499052.309 | 1332104.141 |
| 2 | 499347.626 | 1331478.189 | 36 | 499051.809 | 1332104.854 |
| 3 | 499340.138 | 1331512.635 | 37 | 499051.193 | 1332105.471 |
| 4 | 499335.817 | 1331534.004 | 38 | 499051.119 | 1332105.523 |
| 5 | 499329.029 | 1331559.441 | 39 | 499028.369 | 1332353.685 |
| 6 | 499320.486 | 1331591.964 | 40 | 499028.041 | 1332357.265 |
| 7 | 499316.487 | 1331610.609 | 41 | 499000.796 | 1332653.281 |
| 8 | 499313.892 | 1331622.992 | 42 | 498968.360 | 1333005.574 |
| 9 | 499307.977 | 1331650.579 | 43 | 499300.056 | 1333200.286 |
| 10 | 499299.357 | 1331690.773 | 44 | 499464.795 | 1332414.092 |
| 11 | 499290.295 | 1331731.767 | 45 | 499541.857 | 1332058.984 |
| 12 | 499278.610 | 1331786.697 | 46 | 499578.646 | 1331882.807 |
| 13 | 499269.586 | 1331784.652 | 47 | 499584.066 | 1331857.241 |
| 14 | 499265.524 | 1331783.445 | 48 | 499558.260 | 1331854.971 |
| 15 | 499244.515 | 1331775.980 | 49 | 499558.702 | 1331834.976 |
| 16 | 499229.438 | 1331770.623 | 50 | 499559.043 | 1331819.389 |
| 17 | 499201.358 | 1331760.646 | 51 | 499559.356 | 1331804.901 |
| 18 | 499245.190 | 1331570.923 | 52 | 499557.061 | 1331774.981 |
| 19 | 499256.658 | 1331523.962 | 53 | 499556.525 | 1331766.544 |
| 20 | 499267.192 | 1331464.359 | 54 | 499555.979 | 1331757.961 |
| 21 | 499225.722 | 1331458.170 | 55 | 499556.679 | 1331731.495 |
| 22 | 499167.934 | 1331445.335 | 56 | 499560.294 | 1331716.075 |
| 23 | 499114.252 | 1331429.186 | 57 | 499562.525 | 1331705.884 |
| 24 | 499114.244 | 1331429.310 | 58 | 499564.129 | 1331698.556 |
| 25 | 499112.884 | 1331439.890 | 59 | 499565.409 | 1331692.156 |
| 26 | 499086.774 | 1331716.574 | 60 | 499565.505 | 1331691.160 |
| 27 | 499077.279 | 1331820.155 | 61 | 499566.763 | 1331678.067 |
| 28 | 499077.335 | 1331820.796 | 62 | 499567.164 | 1331676.519 |
| 29 | 499077.324 | 1331821.120 | 63 | 499571.005 | 1331661.712 |
| 30 | 499068.350 | 1331959.498 | 64 | 499573.440 | 1331652.323 |
| 31 | 499068.332 | 1331959.711 | 65 | 499551.421 | 1331646.612 |
| 32 | 499052.950 | 1332102.177 | 66 | 499533.798 | 1331644.280 |
| 33 | 499052.903 | 1332102.509 | 67 | 499494.562 | 1331641.545 |
| 34 | 499052.678 | 1332103.351 | | | |

**សញ្ញាសម្គាល់**

- • និយាមកាចំណុចព្រំដី
- ផ្លូវជាតិលេខ៦ ទទឹង ៦០ ម៉ែត្រ
- ផ្លូវ
- ព្រំដី
- ក្បាលដីស្នើសុំ (០៣០៣០២០៤-១២១២)

**ផ្ទៃក្រឡាដី : ៦៨.៨៥២៦ ហិកតា**

រៀបចំដោយនាយកដ្ឋានបច្ចេកទេស នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ